# ពី Sydenham ទៅ Bankstown

ការបើកផ្លូវសម្រាប់ស៊ីដនីយមេត្រូ

# Southwest Link

## ឡានក្រុងជំនួសរថភ្លើង

# សំណួរដែលគេតែងសួរជាញឹកញាប់

## តើ Southwest Link គឺជាអ្វី?

Southwest Link គឺជាសេវាកម្មរថយន្តក្រុងមានភាពញឹកញាប់ ដែលបានរៀបចំជាពិសេសរវាងស្ថានីយរថភ្លើង Sydenham និង Bankstown ដើម្បីធានាថាអ្នកដំណើរអាចបន្តធ្វើដំណើរ ក្នុងអំឡុងពេលផ្លាស់ប្តូរចុងក្រោយនៃខ្សែរថភ្លើង T3 Bankstown។

### លក្ខណៈសំខាន់ៗនៃ Southwest Link រួមមាន៖

- ផ្លូវឡានក្រុងដែលបានរៀបចំដោយឡែកពិសេសចំនួនបី
- សេវាកម្មញឹកញាប់ជារៀងរាល់ថ្ងៃ ចាប់ពីព្រឹកព្រលឹម រហូតដល់យប់ជ្រៅ ដោយមានឡានក្រុងរៀងរាល់ពីរ ទៅបួននាទី ក្នុងអំឡុងពេលមមាញឹក សម្រាប់ផ្លូវឡានក្រុងមួយចំនួន
- សេវាកម្មចម្រុះដោយឈប់គ្រប់ចំណត និងឈប់នៅចំណតដែលបានកំណត់មួយចំនួន។

Southwest Link បង្កើតជាផ្នែកនៃផែនការដឹកជញ្ជូនរួមបញ្ចូលគ្នា មួយ។

## តើផែនការដឹកជញ្ជូនរួមបញ្ចូលគ្នាគឺជាអ្វី?

ផែនការដឹកជញ្ជូនរួមបញ្ចូលគ្នា គឺជាជម្រើសដឹកជញ្ជូនជំនួសទាំងអស់ដែលមានសម្រាប់អ្នកដំណើរ ដើម្បីជួយដឹកជញ្ជូនទៅដល់កន្លែងដែលពួកគេត្រូវទៅ ក្នុងអំឡុងពេលការងារផ្លាស់ប្តូរខ្សែរថភ្លើង T3 Bankstown។

អ្នកដំណើរអាចជ្រើសរើសពី៖

- ឡានក្រុង Southwest Link
- សេវាកម្មមេត្រូមកជិះ ហើយធ្វើដំណើរចេញនៅ Sydenham
- ឡានក្រុងក្នុងតំបន់
- រថភ្លើង
- ផ្លូវរថភ្លើង light rail
- ផ្លូវជិះកង់ និងផ្លូវដើរ។

## តើ Southwest Link ចាប់ផ្តើមនៅពេលណា ហើយវានឹងដំណើរការរយៈពេលប៉ុន្មានដែរ?

ឡានក្រុង Southwest Link នឹងចាប់ផ្តើមដំណើរការក្នុងរវាងខែកក្កដា និងខែតុលា ឆ្នាំ2024 ហើយនឹងដំណើរការរហូតដល់ទៅ12ខែ។

## តើសេវាកម្ម Southwest Link អាចនឹងចូលប្រើប្រាស់បានដោយជនពិការទេ?

បាទ/ចាស។ អាចចូលប្រើប្រាស់បានដោយជនពិការ ឡានក្រុងដែលអាចបន្ទាបបាននឹងត្រូវបានប្រើពេញទូទាំងផ្លូវឡានក្រុង Southwest Link។

## តើរយៈពេលវេលាធ្វើដំណើររបស់ខ្ញុំនឹងកើនឡើងក្នុងអំឡុងពេលធ្វើឱ្យប្រសើរដែរឬទេ?

បាទ/ចាស។ សូមអនុញ្ញាតឱ្យមានពេលវេលាធ្វើដំណើរបន្ថែម ដើម្បីបញ្ចប់ការធ្វើដំណើររបស់អ្នករវាង Sydenham និង Bankstown ក្នុងអំឡុងពេលធ្វើឱ្យប្រសើរឡើង។ អ្នកនឹងអាចរៀបចំផែនការធ្វើដំណើរតាមរថយន្តក្រុង Southwest Link ក៏ដូចជាស្វែងរកជម្រើសដឹកជញ្ជូនជំនួស មុនពេលសេវាកម្មចាប់ផ្តើម។

## ហេតុអ្វីបានជាខ្សែរថភ្លើង T3 Bankstown រវាង Sydenham ទៅ Bankstown កំពុងត្រូវបានធ្វើឱ្យប្រសើរឡើង?

យើងកំពុងផ្លាស់ប្តូរខ្សែរថភ្លើង T3 Bankstown ដើម្បីបើកសេវាកម្មដឹកអ្នកដំណើរតាមរថភ្លើងមេត្រូកាន់តែលឿន ចាប់ពីឆ្នាំ 2025។

ការងារធ្វើឱ្យប្រសើរឡើងចុងក្រោយអាចចាប់ផ្តើមបាន តែពេលសេវាកម្មរថភ្លើងស៊ីដនីយឈប់ដំណើរការប៉ុណ្ណោះ។ នេះរួមបញ្ចូលទាំងការងារដើម្បីបំបែកខ្សែរថភ្លើងស៊ីដនីយ និងសេវាកម្មរថភ្លើងមេត្រូនៅស្ថានីយ Bankstown, ការធ្វើឱ្យប្រសើរឡើង ស្ថានីយឱ្យបានរួចរាល់ពេញលេញ ការដំឡើងទ្វារអេក្រង់កន្លែងអ្នកដំណើរឡើងចុះនៅស្ថានីយរថភ្លើង ដំឡើងខ្សែភ្លើងនៅខាងលើ ការងារតម្រឹមផ្លូវរថភ្លើងចុងក្រោយ ការធ្វើតេស្តរថភ្លើង និងសកម្មភាពប្រតិបត្តិការ។

ស៊ីដនីយមេត្រូនឹងដំណើរការជាសេវាកម្មបើកមកនិងបើកចេញ ដោយមានរថភ្លើងដំណើរការរៀងរាល់បួននាទីក្នុងអំឡុងពេលម៉ោងមមាញឹក - ពោលគឺ15រថភ្លើងក្នុងមួយម៉ោង។ នៅម៉ោងមមាញឹកបីម៉ោងពេលព្រឹក ស៊ីដនីយមេត្រូនឹងអាចដឹកជញ្ជូនមនុស្ស51,000នាក់ ក្នុងទិសដៅនីមួយៗរវាង Bankstown ទៅកាន់មណ្ឌលពាណិជ្ជកម្មកណ្តាលក្រុងស៊ីដនីយ - ដឹកបានអ្នកដំណើរ15,000នាក់ច្រើនជាងឥឡូវនេះ។



ខាងលើ៖ ការងារផ្លាស់ប្តូរស៊ីដនីយមេត្រូនៅ Hurlstone Park




*ផែនទីមានភាពត្រឹមត្រូវតែក្នុងអំឡុងពេលប្រតិបត្តិការ Southwest Link ប៉ុណ្ណោះ។

## សេវាកម្មរថយន្តក្រុង Southwest Link




## ភាពញឹកញាប់នៃសេវាកម្មរថយន្តក្រុង Southwest Link

**រៀងរាល់2 ទៅ4នាទី**
ក្នុងអំឡុងពេលមមាញឹក

**យ៉ាងហោចណាស់រៀងរាល់10នាទី**
ស្ទើរតែពេញមួយថ្ងៃ

**យ៉ាងហោចណាស់រៀងរាល់15នាទី**
យប់ជ្រៅ

## តើមានការផ្លាស់ប្តូរអ្វីខ្លះសម្រាប់ស្ថានីយរថភ្លើងភាគខាងលិចនៃតំបន់ Bankstown?

តារាងពេលវេលាថ្មីនឹងត្រូវដាក់ឱ្យដំណើរការដោយធានាថា អ្នកដំណើរនៅភាគខាងលិចនៃតំបន់ Bankstown បន្តទទួលបានសេវាកម្មរថភ្លើង។

### ខ្សែរថភ្លើង T3 Liverpool & Inner West

សេវាកម្មរថភ្លើងដែលកំពុងដំណើរការបច្ចុប្បន្នរវាង Liverpool និង City Circle តាមរយៈ Bankstown នឹងបើកទៅកាន់មណ្ឌលពាណិជ្ជកម្មកណ្តាលក្រុងស៊ីដនីយជំនួសវិញ តាមរយៈ Regents Park និង Lidcombe នៅលើខ្សែរថភ្លើង T3 Liverpool & Inner West ថ្មី។ សេវាកម្មនេះគឺដើម្បីរក្សាសេវាកម្មដោយផ្ទាល់ ទៅកាន់មណ្ឌលពាណិជ្ជកម្មកណ្តាលក្រុងស៊ីដនីយពី Berala, Regents Park, Carramar, Villawood, Leightonfield, Chester Hill និង Sefton។

### ខ្សែរថភ្លើងថ្មី T6 Lidcombe & Bankstown

សេវាកម្មរថភ្លើងថ្មីមួយនឹងត្រូវបានដាក់ឱ្យដំណើរការរវាង Lidcombe និង Bankstown។ អ្នកដំណើរនឹងអាចប្តូរគ្នារវាងខ្សែរថភ្លើង T6 Lidcombe & Bankstown Line និង T3 Liverpool & Inner West Line នៅ Regents Park ដើម្បីប្រើសេវាកម្មទៅកាន់មណ្ឌលពាណិជ្ជកម្មកណ្តាលក្រុងស៊ីដនីយ Liverpool ឬ Bankstown។

### ឡានក្រុងជំនួសរថភ្លើង

ពេលខ្លះក្នុងអំឡុងពេលនៃផ្លាស់ប្តូរចុងក្រោយ ឡានក្រុងនឹងជំនួសរថភ្លើងនៅលើខ្សែរថភ្លើង T6 រវាង Lidcombe និង Bankstown ដើម្បីអនុញ្ញាតឱ្យមានការធ្វើឱ្យប្រសើរឡើងដល់ផ្លូវរថភ្លើង និងសកម្មភាពថែទាំ។

## តើមានការផ្លាស់ប្តូរអ្វីខ្លះសម្រាប់អ្នកដំណើរ Erskineville និង St Peters?

អ្នកដំណើរ Erskineville និង St Peters នឹងបន្តទទួលបានសេវាកម្មដោយផ្ទាល់សម្រាប់ទៅ និងមកពីមណ្ឌលពាណិជ្ជកម្មកណ្តាលក្រុងស៊ីដនីយតាមខ្សែរថភ្លើង T8 Airport & South។

## សំបុត្រនៅលើឡានក្រុងជំនួសរថភ្លើង

អ្នកដំណើរត្រូវមានកាត Opal, American Express, Mastercard ឬ Visa card ដែលមានសុពលភាព ដើម្បីបង់ថ្លៃធ្វើដំណើរលើឡានក្រុងជំនួសរថភ្លើង ដោយប៉ះនៅពេលឡើង និងប៉ះនៅពេលចុះ នៅលើម៉ាស៊ីន Opal។

សូមរៀបចំផែនការធ្វើដំណើរជាមុន ហើយទិញកាត Opal តាមអនឡាញ ឬពីអ្នកលក់រាយ Opal។

## តើខ្ញុំអាចតាមដានព័ត៌មានដោយរបៀបណា?

តាមដានព័ត៌មាន និងទទួលបានព័ត៌មានថ្មីៗទាន់ពេលអំពីជម្រើសនៃការដឹកជញ្ជូននៅតាមគេហទំព័រ **transportnsw.info/southwestlink**